ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-May-2021, 10:28
CMS/CFO: Sann Rada

**សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ៦ ខែឧសភា ឆ្នាំ ២០២១**

ភាសា ៖ **អង់គ្លេស និងខ្មែរ**

ចំណាត់ថ្នាក់ឯកសារ ៖ **សាធារណៈ**

---

## សេចក្តីសម្រេចលើសំណើបន្ទាន់របស់ មាស មុត សុំពន្យារពេលឆ្លើយតបទៅនឹងសំណើ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឲ្យបញ្ជូនសំណុំរឿង០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង

---

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា៖**

ជា លាង
Brenda J. HOLLIS

**មេធាវីការពារក្តី មាស មុត**

អាង ឧត្តម
Michael G. KARNAVAS

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖**

ហុង គីមសួន
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ

Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួន ("សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣") លើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី មាស មុត ("មេធាវីការពារក្តី") និងសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ[1]។

២. នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") បានទទួលសំណើពីសហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ")[2]។ នៅក្នុងការទំនាក់ទំនងតាមសារអេឡិចត្រូនិក ក្រឡាបញ្ជីនៃ ក.ស.ច.ស បានបញ្ជាក់ថា សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបានជូនដំណឹងជាផ្លូវការ នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២១ ដូច្នេះ ចម្លើយតបគឺត្រូវដាក់យ៉ាងយូរត្រឹមថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១[3]។

៣. នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ មេធាវីការពារក្តីបានដាក់សំណើសុំពន្យារពេលដាក់ចម្លើយតប ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ("សំណើ")[4]។

៤. នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិបានជូនដំណឹងជាផ្លូវការទៅ ក.ស.ច.ស ថាខ្លួនពុំជំទាស់ទៅនឹងសំណើរបស់មេធាវីការពារក្តីឡើយ[5]។

---

[1] ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១។

[2] ឯកសារ **D270** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅកាន់សហចៅក្រមស៊ើបអង្កេតសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១។

[3] ឯកសារ **D270/1.1** *ឯកសារភ្ជាប់១៖ អ៊ីម៉ែលពី CHANLYDA Chhay មានចំណងជើងថា "យោង៖ កាលបរិច្ឆេទ" ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១* ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១។

[4] ឯកសារ **D270/1** សំណើបន្ទាន់របស់ មាស មុត សុំពន្យារពេលចម្លើយរបស់ខ្លួនតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេតសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១។

[5] ការឆ្លើយឆ្លងតាមរយៈអ៊ីម៉ែលរវាងសហព្រះរាជអាជ្ញាអន្តរជាតិ Brenda J. Hollis និងក្រឡាបញ្ជីរបស់ ក.ស.ច.ស Chanlyda Chhay ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១។ សូមមើល ផងដែរ ឯកសារ **D270/2** ចម្លើយតបរបស់សហ ព្រះ

## II. **អំណះអំណាង**

៥. មេធាវីការពារក្តីស្នើសុំពន្យារពេលមួយសប្តាហ៍ ដើម្បីធ្វើការឆ្លើយតបឲ្យបានត្រឹមត្រូវ ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ បន្ថែមលើនេះ មេធាវីការពារក្តីបានស្នើសុំការអនុញ្ញាតដាក់សារណារបស់ខ្លួនជាភាសាអង់គ្លេសសិន ដោយសំណៅបកប្រែជាភាសាខ្មែរ នឹងដាក់ជូនតាមក្រោយ[6]។

៦. មេធាវីការពារក្តីបានលើកឡើងថា សំណើសុំការពន្យារពេលរបស់ខ្លួន មានភាពចាំបាច់ដើម្បី "ផ្តល់ពេលវេលាគ្រប់គ្រាន់ ក្នុងការដាក់ចម្លើយតបដោយសមហេតុផល និងលម្អិត ចំពោះបញ្ហាដែលបានលើកឡើង" នៅក្នុងសេចក្តីពិចារណាក្នុងសំណុំរឿង០០៣ និងនៅក្នុងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ[7]។

## III. **ការពិភាក្សា**

៧. វិធាន ៣៩(៤) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក បានចែងត្រង់ផ្នែកពាក់ព័ន្ធថា៖

> តាមរយៈពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន សហចៅក្រមស៊ើបអង្កេត [...] អាច៖
>
> ក-ពន្យារពេលវេលាកំណត់ ដែលខ្លួនបានកំណត់ [...]។

៨. សហចៅក្រមស៊ើបអង្កេតពិចារណាថា មេធាវីការពារក្តីបានលើកឡើងនូវមូលដ្ឋានដែលត្រឹមត្រូវតាមច្បាប់ ដើម្បីគាំទ្រដល់សំណើរបស់ខ្លួន។ អាស្រ័យហេតុនេះ ដើម្បីផ្តល់ដល់មេធាវីការពារក្តីនូវពេលវេលាគ្រប់គ្រាន់ ក្នុងការត្រៀមរៀបចំចម្លើយតប ប្រកបដោយប្រសិទ្ធភាព សហចៅក្រមស៊ើបអង្កេត នឹងអនុញ្ញាតផ្តល់ដល់មេធាវីការពារក្តីនូវពេលវេលាបន្ថែមមួយសប្តាហ៍។ បន្ថែមលើនេះ សហចៅក្រមស៊ើប

---

រាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ មាស មុត សុំបន្ថែមពេលវេលាសម្រាប់ដាក់ចម្លើយតបរបស់ គាត់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យសហចៅក្រមស៊ើបអង្កេតបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២១។

[6] ឯកសារ **D270/1** សំណើបន្ទាន់របស់ មាស មុត សុំពន្យារពេលចម្លើយរបស់ខ្លួនតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេតសុំឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២១ ទំព័រ ១។

[7] ដូចយោងខាងលើ កថាខណ្ឌ ៥-៦។

01669280



អង្កេតនឹងអនុញ្ញាតឱ្យមេធាវីការពារក្តីដាក់សារណារបស់ខ្លួនជាភាសាអង់គ្លេសជាមុនសិន ដោយសំណៅបកប្រែជាភាសាខ្មែរនឹងត្រូវដាក់ជូនតាមក្រោយ។

**អាស្រ័យដូចបានរៀបរាប់ពីខាងលើ យើង[8]សម្រេច÷**

៩. **អនុញ្ញាត** តាមសំណើ

១០.**ពន្យារពេល** សម្រាប់មេធាវីការពារក្តី ក្នុងការដាក់ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំនួនមួយសប្តាហ៍បន្ថែម និង

១១. **អនុញ្ញាត** ឱ្យមេធាវីការពារក្តីដាក់សរណារបស់ខ្លួនជាភាសាអង់គ្លេសជាមុនសិន ដោយសំណៅបកប្រែជាភាសាខ្មែរនឹងត្រូវដាក់ជូនតាមក្រោយ។

ភ្នំពេញ ថ្ងៃទី ៦ ខែឧសភា ឆ្នាំ ២០២១

**សហចៅក្រមស៊ើបអង្កេត**

**Co- Investigating Judges**

**Co-juges d'instruction**

**យូ ប៊ុនឡេង** Michael Bohlander

---

[8] ទោះបីចៅក្រមទាំងពីរចុះហត្ថលេខាលើសេចក្តីសម្រេចនេះរួមគ្នាក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតជាតិសូមរំលឹកថា ខ្លួនមិនទទួលស្គាល់ ឬក៏ទទួលយកថាមានសុពលភាពចំពោះឯកសារទាំងឡាយណាដែលបង្កើត និង/ឬ ដាក់ដោយអតីតសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ Laurent Kasper-Ansermet ឡើយ ដូច្នេះ ការដាក់លេខឯកសារក្នុងសំណុំរឿង គួរចាប់ រាប់បន្តពីឯកសារចុងក្រោយដែលដាក់ក្នុងសំណុំរឿងដោយអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Blunk និងមិនរាប់បញ្ចូលឯកសារទាំងឡាយណាដែលដាក់ដោយចៅក្រម Kasper-Ansermet ឡើយ។